អគ្គនាយកដ្ឋានកសិកម្ម

Food and Agriculture Organization of the United Nations

# រុយសជាភ្នាក់ងារចម្លងជំងឺម៉ូសាអ៊ិចលើដំណាំដំឡូងមី

រុយស ស្ថិតក្នុងលំដាប់ Hemiptera គ្រួសារ Aleyrodidae គឺជាពពួកចុចបឺតជញ្ជក់យករុក្ខរសពីរុក្ខជាតិមកចិញ្ចឹមជីវិត។ វាមានដងខ្លួនស្រទន់គ្របដណ្តប់ដោយស្លាបពណ៌ស។ រុយសដែលបំផ្លាញដំណាំដំឡូងមីមានដូចជា៖ *Bemisia tabaci (Gennadius, 1889) Bemisia tabaci (B biotype) (Gennadius, 1889)* និង *Aleurodicus disperses*។



ប្រជារុយស (រូបភាពដោយ Neil Palmer, CIAT)



រុយស (រូបភាពដោយ Stephen Ausmus)



រោគសញ្ញាជំងឺម៉ូសាអ៊ិចលើដំណាំដំឡូងមី (រូបភាពដោយអង្គការ FAO)

## ១. ការបំផ្លាញ

រុយសបំផ្លាញដំណាំដំឡូងមីដោយផ្ទាល់ និងដោយប្រយោល។ ការបំផ្លាញដោយផ្ទាល់គឺវាបឺតជញ្ជក់យករុក្ខរសមកចិញ្ចឹមជីវិតដែលបណ្តាលឲ្យស្លឹកដំឡូងមីឡើងរួញស្លោក និងជ្រុះស្លឹក។ នៅពេលចំនួនប្រជាកររុយសមានកម្រិតខ្ពស់ វានឹងធ្វើឲ្យប៉ះពាល់ទិន្នផលដំឡូងមី។ ចំពោះការបំផ្លាញដោយប្រយោល វាគឺជាភ្នាក់ងារចម្លងជំងឺម៉ូសាអ៊ិចលើដំណាំដំឡូងមី។

## ២. លក្ខណៈរូបសាស្ត្រ

- ពងរុយសមានរាងជាពងក្រពើពណ៌លឿងនិងមានប្រវែងប្រហែល០,២មម។
- សត្វពេញវ័យខ្លួនគ្របដណ្តប់ដោយម្សៅមានពណ៌សរលោង។ វាមានប្រវែងប្រហែល ១មម ហើយសត្វឈ្មោលមានប្រវែងខ្លីជាងសត្វញីបន្តិច។

## ៣. លក្ខណៈជីវសាស្ត្រ

សត្វញីពងនៅផ្នែកក្រោមនៃផ្ទៃស្លឹក។ ពងនឹងញាស់បន្ទាប់ពី៧-១៤ថ្ងៃ។ សត្វពេញវ័យញីមានអាយុប្រមាណពីរសប្តាហ៍ដែលក្នុងមួយវដ្តជីវិតរបស់វា វាអាចពងបានចំនួនពី៦៦-៣០០ពង។ សត្វពេញវ័យសកម្មក្នុងការបឺតជញ្ជក់យករុក្ខរសនៅពេលព្រឹក និងរួមភេទនៅពេលរសៀល។


រុយស (រូបភាពដោយ Ian D. Bedford )


រុយស (រូបភាពដោយ Neil Palmer, CIAT)

## ៤. វិធានការគ្រប់គ្រងរុយស

- សម្អាតស្មៅដែលជាជំរករុយសទាំងក្នុងចម្ការ និងបរិវេណជុំវិញចម្ការ។
- ឆ្លាស់មុខដំណាំដោយដាំឆ្លាស់រវាងដំឡូងមីនឹងដំណាំផ្សេងទៀត ដូចជាពពួកសណ្តែក ពោត។
- រក្សាដីទុកទំនេរមួយរយៈ ដើម្បីផ្តាច់វដ្តជីវិតរុយស។
- ប្រើល្បាយទឹកសាប៊ូ ដែលមានសាប៊ូម្សៅចំនួន ៤ស្លាបព្រា លាយប្រេងឆាចំនួន៨ ស្លាបព្រានិងទឹកចំនួន ១០លីត្រ បាញ់នៅពេលព្រឹក ឬល្ងាច។
- ត្រាំកំណាត់ដំឡូងមី( ពូជ )ក្នុងទឹកថ្នាំទីយ៉ាមេថូសាំ(Thiamethoxam) ១កញ្ចប់ មាន៤ក្រាម លាយទឹក ៨លីត្រ ទុករយៈពេល១០-១៥នាទីមុនពេលដាំ។
- បាញ់ថ្នាំផ្សំពីរុក្ខជាតិ ( ផ្សំស្លឹកទៀប ២គក្រ ស្លឹកប្រេងខ្យល់ ២គក្រ បុកឲ្យម៉ដ្ឋច្របល់ជាមួយទឹក ១០លីត្រ រួចច្រោះឲ្យស្អាតហើយបាញ់កន្លែងដែលកើតរុយស )។
- ក្នុងករណីត្រូវប្រើប្រាស់ថ្នាំកសិកម្ម ត្រូវជ្រើសរើសថ្នាំកសិកម្មណាដែលមានបញ្ជីការត្រឹមត្រូវ។

**រៀបចំដោយ** នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ ក្រោមជំនួយបច្ចេកទេសពីគម្រោងបង្កើនសមត្ថភាពគ្រប់គ្រងការរាតត្បាតនៃជំងឺម៉ូសាអ៊ិចលើដំណាំដំឡូងមី គាំទ្រមូលនិធិដោយអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ

៥៤បេ/៤៩អេហ្វ ផ្លូវលេខ ៣៩៥-៦៥៦ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ
(០២៣) ៨៨៣ ៤២៧ | (០២៣) ៨៨៣ ៤២៧